ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
នាយកដ្ឋានព័ត៌មាន

# សេចក្តីប្រកាសព័ត៌មាន ស្តីពី
# លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការ របស់ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសហុងគ្រី
# ថ្ងៃទី ១១-១២ ខែធ្នូ ឆ្នាំ២០១៨

-----

**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ដំណើរបំពេញទស្សនកិច្ចផ្លូវការនៅហុងគ្រី កាលពីថ្ងៃទី ១១ ដល់ ១២ ខែធ្នូ ឆ្នាំ២០១៨ តបតាមការអញ្ជើញរបស់ **ឯកឧត្តម ភីធើរ ហ្សីអារតូ** រដ្ឋមន្ត្រីការបរទេសនិងពាណិជ្ជកម្មហុងគ្រី។ ទស្សនកិច្ចនេះធ្វើឡើងក្នុងគោលបំណងពង្រឹងទំនុកចិត្តផ្នែកនយោបាយ និងស្វែងរកកិច្ចសហប្រតិបត្តិការក្នុងវិស័យសក្តានុពលដែលផ្តល់ប្រយោជន៍ទៅវិញទៅមក ។

រដ្ឋមន្ត្រីការបរទេសទាំងពីរបានពិភាក្សាគ្នាប្រកបដោយលទ្ធផលផ្លែផ្កា ដែលក្នុងឱកាសនោះ រដ្ឋមន្ត្រីការបរទេសហុងគ្រីបានបញ្ជាក់ជាថ្មីនូវជំហររបស់ហុងគ្រីដែលមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា និងគោរពការសម្រេចចិត្តរបស់ប្រជាជនកម្ពុជាពាក់ព័ន្ធនឹងការបោះឆ្នោតរបស់កម្ពុជា នាពេលថ្មីៗនេះ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានរំលឹកជាមួយនឹងសេចក្តីអំណរគុណ ចំពោះជំនួយ និងការគាំទ្រដ៏មានតម្លៃ និងទាន់ពេលវេលារបស់ហុងគ្រី ចំពោះកម្ពុជាក្នុងកាលៈទេសៈដ៏លំបាកបំផុត បន្ទាប់ពីកម្ពុជាត្រូវបានរំដោះចេញពីរបបខ្មែរក្រហម ព្រមទាំងការរួមចំណែករបស់ហុងគ្រីក្នុងប្រតិបត្តិការថែរក្សាសន្តិភាព ក្រោមក្របខ័ណ្ឌអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (ហៅកាត់ថា អ៊ុនតាក់)។

កិច្ចប្រជុំខាងលើនេះ គឺជាជំនួបលើកទី២រវាងរដ្ឋមន្ត្រីការបរទេសទាំងពីរក្នុងរយៈពេលមិនដល់ ៣ខែនៅក្នុងឆ្នាំ២០១៨នេះ ដែលសបញ្ជាក់ពីការប្តេជ្ញាចិត្តទៅវិញទៅមករបស់រដ្ឋមន្ត្រីទាំងពីរ សំដៅបង្កើតអោយមានកិច្ចសន្ទនាជាទៀងទាត់លើរបៀបវារៈទ្វេភាគីនិងអន្តរជាតិ។ លើសពីនេះទៀត រដ្ឋមន្ត្រីការបរទេសទាំងពីរបានសំដែងនូវការពេញចិត្តចំពោះការរីកចម្រើនកាន់តែខ្លាំងឡើង នៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបានស្តែងឡើងតាមរយៈកិច្ច

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ពិគ្រោះយោបល់ជាទៀងទាត់ ការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ពីស្ថាប័ននិតិប្រតិបត្តិ និងនីតិបញ្ញត្តិ ព្រមទាំងវេទិកាធុរកិច្ច។

ដើម្បីលើកកំពស់ទំនាក់ទំនងជារួមរវាងប្រទេសទាំងពីរអោយកាន់តែខ្លាំងក្លាថែមទៀត ហុងគ្រីនឹងបើកការិយាល័យតំណាងការទូតមួយ នៅរាជធានីភ្នំពេញ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ខាងមុខ។ បន្ថែមលើនេះ ហុងគ្រីបានស្វាគមន៍សំណើតែងតាំងកុងស៊ុលកិត្តិយសរបស់កម្ពុជានៅទីក្រុងប៊ុដាប៉េស្ត។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ចំនួន២ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការលើវិស័យទេសចរនិងវិទ្យាស្ថានការទូតរវាងប្រទេសទាំងពីរ ព្រមទាំងបានឯកភាពធ្វើការងាររួមគ្នា ដើម្បីរៀបចំអោយមានការផ្លាស់ប្តូរទស្សនកិច្ចកម្រិតនាយករដ្ឋមន្ត្រីនាពេលអនាគតដ៏ខ្លី។

រដ្ឋមន្ត្រីការបរទេសទាំងពីរ បានគូសបញ្ជាក់ពីភាពចាំបាច់នៃការបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីអោយស្របទៅនឹងសក្តានុពលដែលមានស្រាប់។ ក្នុងន័យនេះ រដ្ឋមន្ត្រីការបរទេសទាំងពីរបានឯកភាពដាក់ចេញវិធានការមួយចំនួន សំដៅឆ្ពោះទៅរកការបង្កើតគណៈកម្មាធិការសេដ្ឋកិច្ចចម្រុះមួយ ដើម្បីជំរុញភាពជាដៃគូសេដ្ឋកិច្ចនិងពាណិជ្ជកម្មអោយខ្ពស់ថែមមួយកម្រិតទៀត។ លើសពីនេះ រដ្ឋមន្ត្រីការបរទេសទាំងពីរបានកំណត់នូវកិច្ចសហប្រតិបត្តិការលើវិស័យសក្តានុពលជាគន្លឹះមួយចំនួនរួមមាន ការគ្រប់គ្រងទឹក ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងកាកសំណល់ ព្រមទាំងបានឯកភាពគ្នាលើកទឹកចិត្តអោយក្រសួងពាក់ព័ន្ធពិនិត្យលទ្ធភាពស្វែងរកគម្រោងជាក់ស្តែង។ ភាគីទាំងពីរក៏បានសង្កត់ធ្ងន់ផងដែរអំពីតួនាទីដ៏សំខាន់របស់កម្ចីឥណទាន ដែលធនាគារនាំចេញនាំចូលរបស់ហុងគ្រី (EXIM Bank of Hungary) បានត្រៀមផ្តល់ជូន ដើម្បីលើកកំពស់ទំនាក់ទំនងសេដ្ឋកិច្ច និងជួយសហគ្រិនកម្ពុជានិងហុងគ្រី។

សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ហុងគ្រីមានបំណងបង្កើនចំនួនអាហារូបករណ៍ប្រចាំឆ្នាំដល់និស្សិតកម្ពុជា ព្រមទាំងបានសន្យាគាំទ្រសកម្មភាពកំចាត់មីន ដើម្បីជួយកម្ពុជាអោយសម្រេចបាននូវគោលដៅ "ប្រទេសកម្ពុជាគ្មានគ្រាប់មីននៅឆ្នាំ២០២៥"។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ រដ្ឋមន្ត្រីការបរទេសទាំងពីរបានឯកភាពផ្តល់ការគាំទ្រចំពោះគ្នាទៅវិញទៅមកនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ។

ចំពោះទំនាក់ទំនងកម្ពុជានិងសហភាពអឺរ៉ុប ហុងគ្រីបានបញ្ជាក់ជាថ្មីនូវការបន្តការគាំទ្ររបស់ខ្លួន ដើម្បីធានាថា ដំណើរការឆ្ពោះទៅកាន់លទ្ធិប្រជាធិបតេយ្យប្រកបដោយសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា នៅតែបន្តទៅមុខដោយគ្មានការរាំងស្ទះ។ ម្យ៉ាងវិញទៀត ភាគីហុងគ្រីបានយល់ព្រមពិចារណាឡើងវិញនូវជំហររបស់ខ្លួនចំពោះពន្ធលើការនាំចូលអង្ករផ្កាម្លិះរបស់កម្ពុជាចូលទីផ្សារអឺរ៉ុប ហើយបានសន្យាថា នឹងជំរុញអោយសហភាពអឺរ៉ុបបន្តផ្តល់ជំនួយហិរញ្ញវត្ថុដល់កម្ពុជា ដើម្បីជួយដោះស្រាយការប្រឈមផ្នែកអភិវឌ្ឍន៍។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានចូលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម Laszló Kövér** ប្រធានរដ្ឋសភាជាតិនៃប្រទេសហុងគ្រី។ កិច្ចសន្ទនារបស់ភាគីទាំងពីរបានផ្តោតជាសំខាន់លើការលើកកំពស់ភាពជាដៃគូទ្វេភាគីនៅក្នុងវិស័យគ្រប់គ្រងទឹក ឧត្តមសិក្សា និងទេសចរណ៍។ ភាគីហុងគ្រីរីករាយនឹងទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់**សម្តេចប្រធានព្រឹទ្ធសភា** និង **សម្តេចប្រធានរដ្ឋសភា**នៃព្រះរាជាណាចក្រកម្ពុជា នៅទីក្រុងប៊ូដាប៉េស្ត និងស្វាគមន៍តំណាងជាន់ខ្ពស់របស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងកិច្ចប្រជុំកំពូលស្តីពីបញ្ហាទឹកជាសកល (World Water Summit) ដែលគ្រោងនឹងប្រព្រឹត្តទៅនៅខែតុលា ឆ្នាំ២០១៩ នៅប្រទេសហុងគ្រី។

មុនពេលជំនួបសំដែងការគួរសមខាងលើ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ត្រូវបានអញ្ជើញជាភ្ញៀវកិត្តិយស ចូលរួមស្តាប់សម័យប្រជុំពេញអង្គនៃរដ្ឋសភាជាតិហុងគ្រី ដែលក្នុងឱកាសនោះរដ្ឋមន្ត្រីការបរទេសនិងតំណាងរាស្ត្ររបស់ហុងគ្រី កំពុងពិភាក្សាដេញដោលគ្នាលើគោលនយោបាយសំខាន់ៗមួយចំនួន។៕

ថ្ងៃ សុក្រ ៧ កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធស័ក ព.ស.២៥៦២
ភ្នំពេញ ថ្ងៃ ១៤ ខែធ្នូ ឆ្នាំ២០១៨